ក

# មាតិកា

## I~ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


៣០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៦៧ ស្តីពីការបន្ថយរយៈពេលទទួលរងទោស និងលើកលែងទោស ឱ្យទណ្ឌិត ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ចំនួន ៧៣ នាក់ ៣១៩២

៣០-៤-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៤០៩/៤៦៨ ស្តីពីការតែងតាំង ឯកឧត្តម កែវ សាទិន ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ អគ្គនាយក បន្ថែមលើមុខងារបច្ចុប្បន្ន ៣២០១

០២-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៦៩ ស្តីពីការតែងតាំង ឯកឧត្តម ឡេង ម៉ុនគេង ជាឧកញ៉ា ៣២០២

០២-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៧០ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ តាមលំដាប់ថ្នាក់ ជូនចំពោះ ឯកឧត្តម,លោកជំទាវ និងអស់លោក ចំនួន ០៥ រូប ៣២០៣

០២-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៧១ ស្តីពីការប្រោសព្រះរាជទាន គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ចំពោះ ឯកឧត្តមឧកញ៉ា ម៉ឿន សុខណ្ឌ ៣២០៤

០២-៥-២០០៩ -ព្រះរាជក្រឹត្យ នស/រកត/០៥០៩/៤៧២ ស្តីពីការតែងតាំងជំនួយការ ឯកឧត្តម សេរី គុសល ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ចំនួន ០២ រូប ៣២០៥


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


០៥-៥-២០០៩ -អនុក្រឹត្យលេខ ៧២ អនក្រ.បក ស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ៣២០៦

៣០-៤-២០០៩ -អនុក្រឹត្យលេខ ៦២៥ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៣២១៩

៣០-៤-២០០៩ -អនុក្រឹត្យលេខ ៦២៦ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៣២២០

០៥-៥-២០០៩ -អនុក្រឹត្យលេខ ៦២៧ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៣២២១

០៥-៥-២០០៩ -អនុក្រឹត្យលេខ ៦២៨ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៣២២២

០៥-៥-២០០៩ -អនុក្រឹត្យលេខ ៦២៩ អនក្រ.តត ស្តីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ក្រសួងមហាផ្ទៃ ៣២២៣

០៥-៥-២០០៩ -អនុក្រឹត្យលេខ ៦៣០ អនក្រ.តត ស្តីពីការផ្ទេរបញ្ចូលទៅក្នុងក្របខ័ណ្ឌមន្ត្រីក្រមការ ៣២២៥

## ២~សេចក្ដីសំរេច


១១-៥-២០០៩ -សេចក្ដីសំរេចលេខ ៣០ សសរ ស្ដីពីការកែសម្រួលប្រការ ១ នៃសេចក្ដីសម្រេចលេខ ៣៥ សសរ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០១ ស្ដីពីការបង្កើតគណៈកម្មការអន្តរក្រសួងដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់ ៣២៣៦


## III~ការងារបណ្ដាក្រសួង

### ១~ ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល


១១-៥-២០០៩ -ប្រកាសលេខ ៣២៦ ឧរថ.កឧ.ប្រក ស្ដីពីការអនុញ្ញាតឱ្យក្រុមហ៊ុន អង្គរ ស្ត្រីង បង្កើតរោងចក្រ "ផលិតពូកឺស័រ" ៣២៣៨


### ២~ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម


១៨-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥១៧៤ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យ៉ាងស៊ី គ្រុប** ៣២៤៣

១៨-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥១៧៥ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អេច អេហ្វ ខេ ខបភើរេសិន** ៣២៤៥

១៨-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥១៩៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សុវណ្ណ & តិរុណ ហូលឌីង** ៣២៤៧

១៩-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥១៩៧ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **៩ ស៊ី ម៉ាប៊ិល** ៣២៤៩

១៩-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥១៩៨ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **៩ ស៊ី ហូលឌីង** ៣២៥១

១៩-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥១៩៩ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្វង ជា អ៊ឹម-អិម អិច** ៣២៥៣

១៩-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២០០ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ខេមបូឌីហ្សិន ធីភីជី ខូ អិលធីឌី** ៣២៥៥

១៩-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២០១ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សែន ហេង ឌីវេឡុបមេន** ៣២៥៧

១៩-៩-២០០៨ -លិខិតបញ្ជាក់លេខ ៥២០៣ ពណ.ចបព ស្ដីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សឹកសេស ហ្វាម៉ា** ៣២៥៩

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៦៧

**យើង**

**ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ៨ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អ ក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ :

១- ទណ្ឌិតឈ្មោះ **ញឹល ញាណ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៣-១៩៩៩ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥៥ ចុះថ្ងៃទី ០៨-៧-១៩៩៩ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២- ទណ្ឌិតឈ្មោះ **សុត ផាត** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣១-១០-១៩៩៨ ពីបទឃាតកម្មគិតទុកជាមុននិងការកាន់អាវុធខុសពីបទបញ្ជា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៥ ចុះថ្ងៃទី១២-០២-១៩៩៩ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៣- ទណ្ឌិតឈ្មោះ **សេន សល់** ហៅ មាស ស៊ីម ភេទប្រុស អាយុ ២២ ឆ្នាំត្រូវឃុំខ្លួននៅ ថ្ងៃទី ១៧-១០-២០០០ ពីបទ ចោរកម្មប្រើប្រាស់អាវុធហាមឃាត់ដោយខុសច្បាប់ ធ្វើមនុស្សឃាតដោយចេតនា ប្លន់ទ្រព្យសម្បត្តិ ប្រជារាស្ត្រ

ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ "ខ" ចុះថ្ងៃទី ២៤-៤-២០០១ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៤- ទណ្ឌិតឈ្មោះ **សយ ផល្លី** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ៣០-១១-២០០២ ពីបទ រំលោភសេពសន្ថវៈលើកុមារី ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤៦ ចុះថ្ងៃទី ១៩-៣-២០០៣ របស់សាលាដំបូងខេត្តស្វាយរៀង ។

៥- ទណ្ឌិតឈ្មោះ **តេ ភាគ** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៥-៣-២០០២ ពីបទ មនុស្សឃាតដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៩០ ចុះថ្ងៃទី ២១-៨-២០០២ របស់សាលាដំបូងខេត្តស្វាយរៀង ។

៦- ទណ្ឌិតឈ្មោះ **នូ ឡឹក** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-០២-២០០៣ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៧៨ ចុះថ្ងៃទី ១២-៦-២០០៣ របស់សាលាដំបូងខេត្តស្វាយរៀង ។

៧- ទណ្ឌិតឈ្មោះ **គីន នីន** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១០-២០០២ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ០៣ ចុះថ្ងៃទី ៣០-០១-២០០៣ របស់សាលាដំបូងខេត្តរតនគីរី ។

៨- ទណ្ឌិតឈ្មោះ **សៀម ផាន់** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-៦-២០០២ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៥ ឆ្នាំ តាមអំណាចសាលក្រម លេខ២៧ ចុះថ្ងៃទី ២២-៧-២០០២ របស់សាលាដំបូងខេត្តរតនគីរី ។

**មាត្រា ២** : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ២៤ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ :

១- ទណ្ឌិតឈ្មោះ **ព្រៀង លឿង** ភេទប្រុស អាយុ ៤៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៨-៩-២០០០ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ឆ្នាំតាមអំណាចសាលក្រម លេខ៣៥៧ ចុះថ្ងៃទី ០២-១១-២០០០ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២- ទណ្ឌិតឈ្មោះ **ហ៊ាង ម៉ប់** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-១០-២០០១ ពីបទ ឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រម លេខ៦៥ ចុះថ្ងៃទី ២៥-៥-២០០២ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៣- ទណ្ឌិតឈ្មោះ **ឌុល ធារិទ្ធ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-០២-២០០២ ពីបទ ឃាតកម្មគិតទុកជាមុន និងការកាន់អាវុធដែលហាមឃាត់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៥ ចុះថ្ងៃទី១០-៨-២០០២ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

៤- ទណ្ឌិតឈ្មោះ **អ៊ួយ ភួន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-១១-២០០៣ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៦ "ក" ចុះថ្ងៃទី ១៣-៥-២០០៤ របស់សាលាដំបូងខេត្តសៀមរាប-ឧត្ដរមានជ័យ ។

៥- ទណ្ឌិតឈ្មោះ **សូ ផុស** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៤-១២-២០០០ ពីបទ ឃាតកម្ម គិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ៧៥ ចុះថ្ងៃទី ១៦-៥-២០០១ របស់សាលាដំបូងខេត្តសៀមរាប-ឧត្ដរមានជ័យ ។

៦-ទណ្ឌិតឈ្មោះ **នាត សុណា** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៥-៧-២០០៣ ពីបទ រំលោភសេពសន្ថវៈលើកុមារី ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ០១ ចុះ ថ្ងៃទី ០៥-០១-២០០៤ របស់សាលាដំបូងខេត្តស្វាយរៀង ។

៧- ទណ្ឌិតឈ្មោះ **សេក ហាយ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-០២-២០០៣ ពីបទ រំលោភសេពសន្ថវៈលើកុមារី ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១៣ ឆ្នាំ តាមអំណាចសាលក្រម លេខ ៩៧ ចុះ ថ្ងៃទី ១២-៧-២០០៣ របស់សាលាដំបូងខេត្តស្វាយរៀង ។

៨- ទណ្ឌិតឈ្មោះ **ពៅ សៅ** ភេទប្រុស អាយុ ៣៣ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៦-២០០៤ ពីបទ ប៉ុនប៉ង រំលោភសេពសន្ថវៈលើនារីភេទ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រម លេខ ១២៣ ចុះថ្ងៃទី ២៩-១២-២០០៤ របស់សាលាដំបូងខេត្តស្វាយរៀង ។

៩- ទណ្ឌិតឈ្មោះ **គីម ឈៃល** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៤-៤-២០០៤ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំតាមអំណាចសាលក្រម លេខ១០៤ ចុះថ្ងៃទី ១១-១០-២០០៤ របស់សាលាដំបូងខេត្តស្វាយរៀង ។

១០- ទណ្ឌិតឈ្មោះ **ព្រាប ឈាន** ភេទប្រុស អាយុ ៥០ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-១១-២០០៤ ពីបទ ប៉ុនប៉ងសម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាម អំណាចសាលក្រមលេខ ៤៣ ចុះថ្ងៃទី ១២-៥-២០០៥ របស់សាលាដំបូងខេត្តស្វាយរៀង ។

១១- ទណ្ឌិតឈ្មោះ **មូល ឈិន** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៣-៧-២០០១ ពីបទ សម្លាប់មនុស្សដោយចេតនាមានអាវុធ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាច សាលក្រមលេខ ០៣ ចុះ ថ្ងៃទី ១០-០១-២០០២ របស់សាលាដំបូងខេត្តស្វាយរៀង ។

១២- ទណ្ឌិតឈ្មោះ **រំដ្ឋីញ ជូហាទ** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-៦-២០០៣ ពីបទ មនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ០៥ ចុះ ថ្ងៃទី ១០-៣-២០០៤ របស់សាលាដំបូងខេត្តរតនគិរី ។

១៣- ទណ្ឌិតឈ្មោះ **រចំ ធីខ** ភេទប្រុស អាយុ ៤៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២១-៦-២០០២ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ២៨ ចុះថ្ងៃទី ២២-៧-២០០២ របស់សាលាដំបូងខេត្តរតនគិរី ។

ROYAUME DU CAMBODGE * MINISTÈRE DU PALAIS ROYAL *

១៤- ទណ្ឌិតឈ្មោះ **មូ ផល** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៨-១២-២០០០ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ ចុះ ថ្ងៃទី ១២-៧-២០០១ របស់សាលាដំបូងខេត្តរតនគិរី ។

១៥- ទណ្ឌិតឈ្មោះ **ឃុន ឆាំង** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៧-៥-២០០២ ពីបទធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤ ចុះថ្ងៃទី ១២-៦-២០០២ របស់សាលាដំបូងខេត្តរតនគិរី ។

១៦- ទណ្ឌិតឈ្មោះ **ជា ផល្លា** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-១០-២០០១ ពីបទលួងលោមមនុស្សយកទៅធ្វើពេស្យាចារ និងបៀតបៀនកេរខ្មាស ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះ ថ្ងៃទី ០៤-៦-២០០២ របស់សាលាដំបូងខេត្តរតនគិរី ។

១៧- ឈ្មោះ **គង ឆា** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៩-២០០៤ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ២៨ ចុះ ថ្ងៃទី ១៩-៨-២០០៥ របស់សាលាដំបូងខេត្តរតនគិរី ។

១៨- ទណ្ឌិតឈ្មោះ **ជ័យ សារ៉ាត់** ភេទប្រុស អាយុ ១៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៩-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ និងរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ២៨ ចុះថ្ងៃទី ១៩-៨-២០០៥ របស់សាលាដំបូងខេត្តរតនគិរី ។

១៩- ទណ្ឌិតឈ្មោះ **គង់ សោភ័ណ្ឌ** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៥-២០០៥ ពីបទប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះ ថ្ងៃទី ១២-១០-២០០៥ របស់សាលាដំបូងខេត្តរតនគិរី ។

២០- ទណ្ឌិតឈ្មោះ **សាយ សាំងហេង** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៥-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជាពលរដ្ឋ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤១ ចុះ ថ្ងៃទី ១២-១០-២០០៥ របស់សាលាដំបូងខេត្តរតនគិរី ។

២១- ទណ្ឌិតឈ្មោះ **សាក់ឆៃ ភាវតាន់** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៩-៨-២០០២ ពីបទ ទិញគ្រឿងញៀនដោយខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ "ក" ចុះថ្ងៃទី ១៧-០១-២០០៣ របស់សាលាដំបូងខេត្តបាត់ដំបង ។

២២- ទណ្ឌិតឈ្មោះ **មិន ជា** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៤-១១-២០០២ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨ "គ" ចុះថ្ងៃទី ១២-៣-២០០៣ របស់សាលាដំបូងខេត្តបាត់ដំបង ។

២៣- ទណ្ឌិតឈ្មោះ **វង្ស សុវណ្ណ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៥-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ [illegible] "ខ" ចុះថ្ងៃទី ០៦-៨-២០០៤ របស់សាលាឧទ្ធរណ៍ ។



២៤- ទណ្ឌិតឈ្មោះ **ជួប ទាំន់** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៥-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៤៩ "ខ" ចុះថ្ងៃទី ០៦-៨-២០០៤ របស់សាលាឧទ្ធរណ៍ ។

**មាត្រា ៣ :** ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ៣០ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ :

១- ទណ្ឌិតឈ្មោះ **ឌុយ ឌុំ** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-១២-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ០២ ចុះថ្ងៃទី ០៨-០១-២០០២ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២- ទណ្ឌិតឈ្មោះ **ម៉ក់ រុន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៤-១០-២០០៤ ពីបទ រំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ៨៧ "ក" ចុះថ្ងៃទី ១៩-៥-២០០៤ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៣- ទណ្ឌិតឈ្មោះ **ម៉ែន ខ្ញុំយ** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១១-២០០៤ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "ឃ" ចុះថ្ងៃទី ១៣-៦-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៤- ទណ្ឌិតឈ្មោះ **ឡាយ សុខ** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១២-១១-២០០៤ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "ឃ" ចុះថ្ងៃទី ១៣-៦-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៥- ទណ្ឌិតឈ្មោះ **ចាំង ឌីនធីចាន** ភេទស្រី អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-០២-២០០៥ ពីបទសញ្ជារកម្ម ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣៤ "ក" ចុះថ្ងៃទី ១៥-៨-២០០៥ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៦- ទណ្ឌិតឈ្មោះ **សុខ ណាម** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៨-៧-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤ "គ" ចុះថ្ងៃទី ០៨-០២-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៧- ទណ្ឌិតឈ្មោះ **ជឹម សុវណ្ណ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០២-៥-២០០៤ ពីបទប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ១០៦ ចុះថ្ងៃទី ២៦-១០-២០០៤ របស់សាលាដំបូងខេត្តស្វាយរៀង ។

៨- ទណ្ឌិតឈ្មោះ **សួន សាម៉ែ** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៦-១០-២០០៣ ពីបទ រួបរួមគ្នាប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤ ចុះថ្ងៃទី ១៩-៤-២០០៤ របស់សាលាដំបូងខេត្តស្វាយរៀង ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

៩- ទណ្ឌិតឈ្មោះ **ម៉ា សៅ** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៥-២០០៦ ពីបទ រួបរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រម លេខ៦៧ ចុះថ្ងៃទី ២៦-៩-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

១០- ទណ្ឌិតឈ្មោះ **ម៉ែន មិច** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៥-២០០៦ ពីបទ រួបរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ៦៧ ចុះថ្ងៃទី ២៦-៩-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

១១- ទណ្ឌិតឈ្មោះ **ម៉ែន សេន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-៥-២០០៦ ពីបទ រួបរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ៦៧ ចុះថ្ងៃទី ២៦-៩-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

១២- ទណ្ឌិតឈ្មោះ **ចាប រិន** ភេទប្រុស អាយុ ៣៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-៥-២០០៦ ពីបទ រួបរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ៦៧ ចុះថ្ងៃទី ២៦-៩-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

១៣- ទណ្ឌិតឈ្មោះ **នាង ឡៀន** ភេទប្រុស អាយុ ៣១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-៧-២០០៦ ពីបទ រួបរួមគ្នាប្លន់ប្រដាប់អាវុធ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៧ ចុះថ្ងៃទី ២៦-៩-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង។

១៤- ទណ្ឌិតឈ្មោះ **ថោង ទិសាល** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១០-២០០៦ ពីបទរួបរួមគ្នាប្លន់ទ្រព្យសម្បត្តិរបស់អ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ "គ" ចុះថ្ងៃទី ០៦-០២-២០០៧ របស់សាលាដំបូងខេត្តស្វាយរៀង ។

១៥- ទណ្ឌិតឈ្មោះ **សុខ សារឿន** ភេទប្រុស អាយុ ៤៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៦-១២-២០០៦ ពីបទប្លន់ទ្រព្យសម្បត្តិផ្ទាល់របស់ប្រជារាស្ត្រហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ "គ" ចុះថ្ងៃទី ០៧-៦-២០០៧ របស់សាលាដំបូងខេត្តស្វាយរៀង ។

១៦- ទណ្ឌិតឈ្មោះ **វត្ថ័ ណារ៉ាក់** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៨-១០-២០០៥ ពីបទ បង្ករបួសស្នាមដោយចេតនាមានអាវុធ លើព្រះសង្ឃ និងដូនជី ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ៥២ ចុះថ្ងៃទី ០១-៨-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

១៧- ទណ្ឌិតឈ្មោះ **រួម ឡុត** ភេទប្រុស អាយុ ៤៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៤-២០០២ ពីបទ ក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាម អំណាចសាលក្រមលេខ ៤៧ "ខ" ចុះថ្ងៃទី ០៦-៨-២០០២ របស់សាលាដំបូងខេត្តបាត់ដំបង ។

១៨- ទណ្ឌិតឈ្មោះ **ទ្រី ពៅ** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-០១-២០០៤ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ [illegible]" ចុះថ្ងៃទី ១០-៦-២០០៤ របស់សាលាដំបូងខេត្តបាត់ដំបង ។

ROYAUME DU CAMBODGE
ក្រសួងព្រះបរមរាជវាំង
MINISTRE DU PALAIS ROYAL

១៩- ទណ្ឌិតឈ្មោះ **ឡុង សម្បត្តិ** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៩-៤-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៩៤ "ខ" ចុះថ្ងៃទី ០៦-៩-២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ។

២០- ទណ្ឌិតឈ្មោះ **អ៊ឹម ធឿន** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១០-០១-២០០៥ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រម លេខ ៤៨ "ខ" ចុះថ្ងៃទី ១៩-៤-២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ។

២១- ទណ្ឌិតឈ្មោះ **ឆន រិន** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០១-០២-២០០៥ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៧ "ក" ចុះថ្ងៃទី ០៣-៦-២០០៥ របស់សាលាដំបូងខេត្តបាត់ដំបង ។

២២- ទណ្ឌិតឈ្មោះ **ព្រុំ ចរិន្ទ** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-៧-២០០៥ ពីបទ លក់-ទិញ គ្រឿងញៀនខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាច សាលក្រម លេខ ០៣ "ខ" ចុះថ្ងៃទី ០៣-០១-២០០៦ របស់សាលាដំបូងខេត្តបាត់ដំបង ។

២៣- ទណ្ឌិតឈ្មោះ **ហ៊ា ហ៊ាន** ភេទប្រុស អាយុ ៣៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-៣-២០០៦ ពីបទ ប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១១៤ "ក" ចុះ ថ្ងៃទី ០២-១០-២០០៦ របស់សាលាដំបូងខេត្តបាត់ដំបង ។

២៤- ទណ្ឌិតឈ្មោះ **ព្រុំ ធឿន** ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-០១-២០០២ ពីបទ ប្លន់ ប្រើប្រាស់អាវុធខុសច្បាប់ សមគំនិតក្នុងបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៩ ឆ្នាំ ៦ ខែ តាមអំណាចសាលក្រមលេខ ៦៥ ចុះថ្ងៃទី ២៦-៨-២០០២ របស់សាលាដំបូងខេត្តក្រចេះ ។

២៥- ទណ្ឌិតឈ្មោះ **ត្រឹម សុធី** ភេទប្រុស អាយុ ៤៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៤-២០០៥ ពីបទ ប្លន់គាស់ទំលុះទំលាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៣ ចុះថ្ងៃទី ២៧-០១-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

២៦- ទណ្ឌិតឈ្មោះ **លន ម៉ុណ្ណារ៉េត** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៤-២០០៥ ពីបទ ប្លន់គាស់ទំលុះទំលាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ៣៣ ចុះថ្ងៃទី ២៧-០១-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

២៧- ទណ្ឌិតឈ្មោះ **សេង ស្រាង** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១២-២០០៤ ពីបទ ប្លន់ ទ្រព្យសម្បត្តិអ្នកដទៃ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦ ចុះថ្ងៃទី ២៨-៤-២០០៥ របស់សាលាដំបូងខេត្តក្រចេះ ។

២៨- ទណ្ឌិតឈ្មោះ **អ៊ុយ អ៊ឹម** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៨-៨-២០០៥ ពីបទ ប្លន់ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៤ ចុះថ្ងៃទី ១២-៩-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

២៩- ទណ្ឌិតឈ្មោះ **អាង ថាង** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៧-២០០៥ ពីបទប្លន់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី ២៣-៣-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

៣០- ទណ្ឌិតឈ្មោះ **នូ ធី** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៩-៧-២០០៥ ពីបទ ប្លន់ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៦០ ចុះថ្ងៃទី ២៣-៣-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

**មាត្រា ៤ :** ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ១១ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ដូចមានរាយឈ្មោះខាងក្រោមនេះ :

១- ទណ្ឌិតឈ្មោះ **ឡាន ឡាយ** ភេទប្រុស អាយុ ៤១ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-៩-២០០០ ពីបទឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៨ ចុះថ្ងៃទី ២៨-៣-២០០១ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

២- ទណ្ឌិតឈ្មោះ **ចាន់ កែវចណាទី** ហៅ ចាន់ សុខុម ភេទស្រី អាយុ ៤៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-៨-២០០៥ ពីបទ ឆបោក ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ "គ" ចុះថ្ងៃទី ២០-០២-២០០៦ របស់សាលាដំបូងខេត្តសៀមរាប-ឧត្តរមានជ័យ ។

៣- ទណ្ឌិតឈ្មោះ **ទ្រាង ស៊ីន** ភេទស្រី អាយុ ៤៨ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៣-០២-២០០១ ពីបទរួមគ្នាពង្រត់មនុស្សយកទៅលក់ និងយកទៅធ្វើពេស្យាចារ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៤ ចុះថ្ងៃទី ១៩-៧-២០០១ របស់សាលាដំបូងខេត្តស្វាយរៀង ។

៤- ទណ្ឌិតឈ្មោះ **ជឿន សុវណ្ណ** ភេទប្រុស អាយុ ៤៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-៥-២០០៦ ពីបទរួមគ្នាលក់ចែកចាយគ្រឿងញៀនដោយខុសច្បាប់ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ៧៨ ចុះថ្ងៃទី ១០-១០-២០០៦ របស់សាលាដំបូងខេត្តស្វាយរៀង ។

៥- ទណ្ឌិតឈ្មោះ **ម៉ែន ធឿន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៦-៥-២០០៥ ពីបទ ប្លន់ និងមនុស្សឃាតគិតទុកជាមុន បង្ករបួសស្នាមដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ២២ ចុះថ្ងៃទី ៣១-៨-២០០៦ របស់សាលាដំបូងខេត្តរតនគិរី ។

៦- ទណ្ឌិតឈ្មោះ **សារី ធី** ហៅ ខ្ញិន ភេទប្រុស អាយុ ២៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១១-២០០១ ពីបទ ធ្វើមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រម លេខ ០១ ចុះថ្ងៃទី ២២-០១-២០០២ របស់សាលាដំបូងខេត្តរតនគិរី ។

៧- ទណ្ឌិតឈ្មោះ **ចាយ ចិន** ភេទប្រុស អាយុ ៣៩ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ០៣-៤-២០០២ ពីបទ ក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤៧ "ខ" ចុះថ្ងៃទី ០៦-៨-២០០២ របស់សាលាដំបូងខេត្តបាត់ដំបង ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៨- ទណ្ឌិតឈ្មោះ **មាន សំណាង** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២៥-១១-២០០៣ ពីបទប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រម លេខ ១២ "គ" ចុះថ្ងៃទី ២៥-០២-២០០៤ របស់សាលាដំបូងខេត្តបាត់ដំបង ។

៩- ទណ្ឌិតឈ្មោះ **អំ ប្រ៊ុចឆាន** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-១៩៩៥ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រម លេខ ៣៦ ចុះថ្ងៃទី ០១-១២-១៩៩៥ របស់សាលាដំបូងខេត្តក្រចេះ ។

១០- ទណ្ឌិតឈ្មោះ **អំ ប្រ៊ុចអាន** ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-៥-១៩៩៥ ពីបទមនុស្សឃាតគិតទុកជាមុន ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៩ ឆ្នាំ តាមអំណាចសាលក្រម លេខ ៣៦ ចុះថ្ងៃទី ០១-១២-១៩៩៥ របស់សាលាដំបូងខេត្តក្រចេះ។

១១- ទណ្ឌិតឈ្មោះ **ទ្វី ឆៃគីម** ភេទប្រុស អាយុ ៤២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៤-២០០៥ ពីបទប្លន់គាស់ទំលុះទំលាយ ហើយត្រូវតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រម លេខ៣៣ ចុះថ្ងៃទី ២៧-០១-២០០៦ របស់សាលាដំបូងខេត្តក្រចេះ ។

**មាត្រា ៥ : សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៦ :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

នស/រកត.០៥០៤.៤៧០

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ,ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ២០០៥

លេខ : ៤៦៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែឧសភា ឆ្នាំ២០០៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ជិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៤០៩/៤៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដាឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំង ឯកឧត្តម **កែវ សារិន** ជាទីប្រឹក្សាអមក្រសួងសាធារណការ និងដឹកជញ្ជូន មានឋានៈស្មើ **អគ្គនាយក** បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

៣រល.០៩០៤.៤៧៦

លេខ : ៤៧៥ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩

ចម្លងចេញពីច្បាប់ដើម

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ ២០០៩

អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុំ ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៦៩

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

## តែងតាំង

ឯកឧត្តម ឡេង ម៉ិនគេង

ជា

## ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៥.៤៧២

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ : ៤៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ២០០៩
អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ស៊ុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេរីវឌ្ឍន៍ ជូនចំពោះ :

១-ឯកឧត្តម ហួន ចន្ទកក្កដា

- គ្រឿងឥស្សរិយយស មុនីសារាភ័ណ្ឌ ថ្នាក់ មហាសេនា ជូនចំពោះ :

១-លោកជំទាវ ម៉ុន ចន្ទនីណា
២-លោកឧត្តមសេនីយ៍ទោ គុល គីមលី
៣-លោក ហ៊ីន យុទនា
៤-លោក ហខៀ សាទុធ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៩០៥.៤៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩

លេខ : ៤២៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល

ស៊ុន ចាន់ថុល

ឃុន ជិនកេន

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

ប្រោសព្រះរាជទាន

- គ្រឿងឥស្សរិយយស ព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា ជូនចំពោះ :

ឯកឧត្តមឧកញ៉ា ខឿន សុវណ្ណ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣រល.០៩០៥.៤៧៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩

លេខ : ៤៣៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ២០០៩
អគ្គលេខាធិការរងទីស្តីការគណៈរដ្ឋមន្ត្រី

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៥០៩/៤៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ត្រូវបានតែងតាំងជំនួយការឯកឧត្តម **សៅ រ៉ុសុល** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ដូចមានរាយនាមខាងក្រោម ÷

១-ឯកឧត្តម **ប្រាក់ សុភាព** មានឋានៈស្មើ អគ្គនាយក

២-ឯកឧត្តម **យឹម សារគន្ធ** មានឋានៈស្មើ អគ្គនាយក

**មាត្រា ២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៩០៥.៤៧៥

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០៩*

លេខ ៤៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០០៩

អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## នីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់

******

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៦/០១១ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីជលផល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៧/០១៦ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងធនធានទឹកនៅក្នុងព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

- បានឃើញអនុក្រឹត្យលេខ១២៩ អនក្រ.បក ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ ._**

អនុក្រឹត្យនេះមានគោលដៅកំណត់គោលការណ៍ យន្តការ និងនីតិវិធីសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ។

**មាត្រា ២ ._**

អនុក្រឹត្យនេះមានគោលបំណង ៖

- ផ្តល់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ រៀបចំផែនការគ្រប់គ្រងនិងប្រើប្រាស់ធនធានដី និងធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាព
- គាំទ្រកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមប្រកបដោយនិរន្តរភាព និងសមធម៌
- រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ
- ជួយឱ្យសម្រេចបាននូវផលិតភាពខ្ពស់នៃការប្រើប្រាស់ដីក្នុងមូលដ្ឋានឃុំ សង្កាត់ ស្របតាមស្ថានភាពដីជាក់ស្តែង និងសក្តានុពលធម្មជាតិនៃដី
- ឆ្លើយតបចំពោះសេចក្តីត្រូវការជីវរបស់អាជ្ញាធរនានា និងរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់
- ជួយការពារធនធានដី និងធនធានធម្មជាតិផ្សេងៗទៀតមិនឱ្យបាត់បង់គុណភាព និងមិនឱ្យប្រើប្រាស់ខុសទិសដៅ
- រួមចំណែកក្នុងការកំណត់ និងគ្រប់គ្រងដីរដ្ឋដែលមាននៅក្នុងឃុំ សង្កាត់ ឱ្យបានល្អប្រសើរតាមតួនាទីជាភ្នាក់ងារតំណាងរដ្ឋរបស់ក្រុមប្រឹក្សាឃុំ សង្កាត់
- ស្វែងរកការគាំទ្រផ្នែកបច្ចេកទេសពីស្ថាប័ន អង្គភាពនានា និងពីផ្នែកឯកជន ដើម្បីបំពេញបន្ថែមចំពោះការរៀបចំកសាងផែនការអភិវឌ្ឍឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់ ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ព្រមទាំងដីឯកជនរបស់បុគ្គលឯកជនដែលស្ថិតនៅក្នុងឃុំ សង្កាត់ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤ .-**

វាក្យសព្ទខាងក្រោមប្រើក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ ÷

- **ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជនរបស់បុគ្គលឯកជន ។
- **ផែនការអភិវឌ្ឍឃុំ សង្កាត់** សំដៅដល់ផែនការអភិវឌ្ឍនានាដែលបានអនុម័តជាផ្លូវការរួចហើយសម្រាប់ ឃុំ សង្កាត់ទាំងមូល ដើម្បីឱ្យឃុំ សង្កាត់នោះមានការរីកចម្រើនជាទូទៅ ជាពិសេសផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងធ្វើឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងឃុំ សង្កាត់នោះបានល្អប្រសើរជាលំដាប់ ។
- **កម្មវិធីវិនិយោគនៅឃុំ សង្កាត់** សំដៅដល់កម្មវិធីវិនិយោគសម្រាប់រយៈពេល ០១ (មួយ) ឆ្នាំ ដែលជាឧបករណ៍ចាំបាច់សម្រាប់អនុវត្តឱ្យសម្រេចបាននូវចក្ខុវិស័យ ទិសដៅ និងយុទ្ធសាស្ត្រនានាដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍឃុំ សង្កាត់ ។
- **ផែនទីរដ្ឋបាលឃុំ សង្កាត់** សំដៅដល់ផែនទីរដ្ឋបាលដែលចេញផ្សាយដោយនាយកដ្ឋានភូមិសាស្ត្រនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។
- **ផែនទីប្រើប្រាស់ដីឃុំសង្កាត់** សំដៅដល់ផែនទីដែលមានព័ត៌មានស្តីពីប្រភេទនៃការប្រើប្រាស់ដី គម្របដីព្រៃប្រទល់ និងទីតាំងរដ្ឋបាលឃុំសង្កាត់ដែលមានកន្លងមក ។

## ជំពូកទី២

## គោលការណ៍សម្រាប់រៀបចំផែនការ

**មាត្រា ៥ .-**

ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ÷

១. ត្រូវធ្វើតាមវិធីសាស្ត្រដែលមានលក្ខណៈចូលរួម ដោយឱ្យមានការចូលរួមពីអ្នកពាក់ព័ន្ធពីគ្រប់ភូមិទាំងអស់នៃឃុំ សង្កាត់នីមួយៗ ព្រមទាំងពីក្រុមសង្គមស៊ីវិលដែលមានការពាក់ព័ន្ធនឹងការងារដីធ្លី ។

២. ត្រូវស្របតាមគម្រោងផែនការអភិវឌ្ឍដែលមានជាផ្លូវការនៅថ្នាក់ឃុំ សង្កាត់ ដែលអាចជាប្រភេទនៃការអភិវឌ្ឍចម្រុះ ឬជាប្រភេទនៃការអភិវឌ្ឍផ្នែកតាមប្រភពធនធានជាក់លាក់នីមួយៗតាមទស្សនៈភូមិមួយផលិតផលមួយ ឬតាមលក្ខណៈពិសេសជាក់លាក់របស់តំបន់នីមួយៗ ។

៣. ត្រូវយកផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ធ្វើជាមូលដ្ឋានបង្អែកសម្រាប់រៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់។

៤. ត្រូវតែបើកចំហរាល់ព័ត៌មានទាំងអស់ចំពោះគ្រប់ភាគីពាក់ព័ន្ធទាំងអស់។

៥. ត្រូវផ្តល់អាទិភាពខ្ពស់ដល់តម្រូវការដីនៅមូលដ្ឋាន ឃុំ សង្កាត់សាមី នាពេលបច្ចុប្បន្ន និងទៅអនាគតសម្រាប់រយៈពេលពី ១០ (ដប់)ទៅ ១៥ (ដប់ប្រាំ) ឆ្នាំខាងមុខ សម្រាប់សេវា និងការប្រើប្រាស់ជាសាធារណៈសម្រាប់ការដោះស្រាយការតាំងទីលំនៅថ្មីដែលបណ្តាលមកពីគម្រោងអភិវឌ្ឍរបស់រដ្ឋ គម្រោងអភិវឌ្ឍរបស់មូលដ្ឋាន គ្រោះធម្មជាតិផ្សេងៗ ឬកំណើនប្រជាពលរដ្ឋ តាមរយៈការបម្រុងដីទុកសម្រាប់គោលដៅជាក់លាក់នីមួយៗស្របតាមបញ្ញត្តិច្បាប់ទាំងឡាយដូចជា ការផ្តល់ដីតាមរយៈសម្បទានដីសង្គមកិច្ចជាដើម។

៦. ធ្វើផែនការប្រើប្រាស់ដីមិនមែនជាការផ្តល់ដីឬបែងចែកដីជាក់ស្តែងនោះទេ។

## ជំពូកទី៣
## យន្តការ និងភារកិច្ច

**មាត្រា ៦ .-**

យន្តការសម្រាប់ការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ មានដូចតទៅ ÷

១. ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន ផ្តល់ព័ត៌មានជាក់លាក់នានា រៀបចំកិច្ចពិភាក្សា ការពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ ជាមួយប្រជាជនក្នុងភូមិ ដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីជាលក្ខណៈផែនការលំអិតនិងជាម្ចាស់នៃផែនការប្រើប្រាស់ដីឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់តាំងជនបង្គោលមួយ ឬច្រើនរូបឱ្យទទួលខុសត្រូវក្នុងការសម្របសម្រួល និងធ្វើទំនាក់ទំនងជាប្រចាំជាមួយក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ លើការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

២. ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដែលមានសមាសភាពតាមការកំណត់ដោយមាត្រា ២៧ នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចសំខាន់ក្នុងការសម្របសម្រួលផ្តល់ការគាំទ្រផ្នែកបច្ចេកទេសចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងជួយកៀរគរការគាំទ្រពីភាគីពាក់ព័ន្ធនានា។ ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ

ដើម្បីធ្វើការជាប្រចាំជាមួយក្រុមប្រឹក្សា ឃុំ សង្កាត់ និងមន្ត្រីបច្ចេកទេសនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។

៣. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តដែលមានសមាសភាពតាមការកំណត់ដោយមាត្រា ២៤ នៃអនុក្រឹត្យលេខ ១១៨ អនក្រ ប.ក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ មានភារកិច្ចពិនិត្យឡើងវិញ ផ្តល់យោបល់កែសម្រួល សម្រេច និងត្រួតពិនិត្យការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់។

**មាត្រា ៧ .-**

ក្រុមប្រឹក្សាឃុំ សង្កាត់ មានភារកិច្ចដូចតទៅ÷

- ស្រង់ និងផ្តល់ទិន្នន័យនៃការប្រើប្រាស់ដីជាក់ស្តែងកន្លងមក
- ធ្វើការសិក្សា និងបង្ហាញអំពីសេចក្តីត្រូវការដីរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានឃុំ សង្កាត់របស់ខ្លួន និងពិចារណាអំពីការរៀបចំគម្រោងផែនការអភិវឌ្ឍឃុំ សង្កាត់ ព្រមទាំងកិច្ចសហការចាំបាច់ផ្សេងទៀតក្នុងដំណើរការរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ជូនដំណឹង និងបិទផ្សាយជាសាធារណៈនូវលទ្ធផលនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដែលគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត បានផ្តល់យោបល់កែសម្រួលរួច
- ប្រមូល និងសង្ខេបមតិយោបល់សាធារណៈជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ក្រោយការបិទផ្សាយជាសាធារណៈ
- លើកសំណើសុំកែប្រែផែនការទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត តាមរយៈក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងមាត្រា ១៨ នៃអនុក្រឹត្យនេះ
- តាមដាន និងវាយតម្លៃការអនុវត្តផែនការ និងធ្វើរបាយការណ៍ប្រចាំឆមាស ប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត។ មេឃុំ ចៅសង្កាត់មានភារកិច្ចដឹកនាំកិច្ចប្រជុំនានាពាក់ព័ន្ធដល់ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ និងទទួលខុសត្រូវលើការអនុវត្តផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ដែលបានអនុម័តរួចហើយ។

**មាត្រា ៨ .-**

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ មានភារកិច្ចដូចតទៅ÷

- ដឹកនាំការប្រជុំដើម្បីរៀបចំធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ធ្វើការវាយតម្លៃសេចក្តីត្រូវការដី ស្ថានភាពជាក់ស្តែងនៃដី និងសក្តានុពលដី ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធ

- រួមសហការជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ លើកសំណើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ដោយមានសេចក្តីអធិប្បាយអំពីសេចក្តីត្រូវការដីរបស់មូលដ្ឋាន ស្ថានភាពជាក់ស្តែងនៃដីនិងសក្តានុពលដី និងគម្រោងរៀបចំផែនការអភិវឌ្ឍផ្សេងៗទៅអនាគតរបស់ឃុំ សង្កាត់
- ជួយធ្វើការកែតម្រូវគម្រោងផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមការសម្រេចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត
- ជំរុញការអនុវត្តផែនការប្រើប្រាស់ដី ដែលបានសម្រេចជាផ្លូវការ និងជួយរៀបចំរបាយការណ៍បូកសរុបប្រចាំឆមាស និងឆ្នាំ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត អំពីការអនុវត្តផែនការប្រើប្រាស់ដី ជាពិសេសដីដែលបានផ្តល់ ឬចែកឱ្យបុគ្គលឯកជន សមូហភាព ឬអង្គភាពរដ្ឋនានា នៅថ្នាក់ក្រុង ស្រុក ខណ្ឌ និងដីដែលនៅសល់ក្នុងផែនការមិនទាន់បានបែងចែក ព្រមទាំងដីដែលស្ថិតនៅក្រោមការគ្រប់គ្រងកាន់កាប់របស់អាជ្ញាធរកាន់កាប់ដីរដ្ឋដែលមានក្នុងឃុំ សង្កាត់នោះ
- ដោះស្រាយទំនាស់ពាក់ព័ន្ធនឹងការប្រើប្រាស់ដីរវាងឃុំ សង្កាត់ និងឃុំ សង្កាត់
- ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ។ សមាសភាពក្រុមនេះអាចមានពី ៣ (បី)ទៅ ៥ (ប្រាំ) នាក់ ដែលជាមន្ត្រីបច្ចេកទេសពីការិយាល័យជំនាញជុំវិញក្រុង ស្រុក ខណ្ឌ។

**មាត្រា ៩ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត មានភារកិច្ចដូចតទៅ ÷

- ដឹកនាំពិគ្រោះយោបល់សម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្នុងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ផ្តល់យោបល់ដល់ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការកែសម្រួលផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ដោយពិចារណាជាមួយប្លង់មេ ផែនការអភិវឌ្ឍផ្សេងៗ និងការកំណត់តំបន់ប្រើប្រាស់ដីទាំងឡាយដែលបានសម្រេចជាផ្លូវការរួចហើយ
- សម្រេច និងត្រួតពិនិត្យលើការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- ចាត់តាំងបង្កើតក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់រាជធានី ខេត្ត ដែលសមាសភាពក្រុមនេះអាចមានពីបី (៣) ទៅប្រាំ (៥) នាក់ ជាមន្ត្រីបច្ចេកទេសពីមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ហើយមានភារកិច្ចសំខាន់ ជួយសម្របសម្រួលការងារអង្គភាពពាក់ព័ន្ធនៅជុំវិញរាជធានី ខេត្ត និងធ្វើជាគ្រូបណ្តុះបណ្តាលការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំសង្កាត់

- បូកសរុប និងលើកផែនការសកម្មភាពនិងគម្រោងថវិកាប្រចាំឆ្នាំសម្រាប់គាំទ្រការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់
- បំពេញភារកិច្ចផ្សេងទៀតដែលពាក់ព័ន្ធនឹងការងាររៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ឬរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

## ជំពូកទី៤
## នីតិវិធីនៃការរៀបចំផែនការ

**មាត្រា ១០ .-**

ការរៀបចំផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ ត្រូវអនុវត្តដូចខាងក្រោម ÷

